ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៤៨ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

២៤-១២-៩៦ ព្រះរាជក្រម នស/រកម/១២.៩៦/៣៤ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុញ្ញាស្តីពីតំបន់ដីសើម មានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជំរកសត្វស្លាបទឹក ២០១៧

២៤-១២-៩៦ ព្រះរាជក្រម នស/រកម ១២៩៦/៣៥ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្រមខ័ណ្ឌនៃសហប្រជាជាតិ ស្តីពីការផ្លាស់ប្តូរធាតុអាកាស ២០១៩

២៤-១២-៩៦ ព្រះរាជក្រម នស/រកម/១២៩៦/៣៦ ច្បាប់ស្តីពីកិច្ចការការពារបរិស្ថាន និង ការគ្រប់គ្រង និង ការគ្រប់គ្រងធនធានធម្មជាតិ ។ ២០២២

២៤-១២-៩៦ ព្រះរាជក្រម នស/រកម ១២៩៦/៣៧ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ២០២៣

២ - ព្រះរាជក្រឹត្យ

២៣-១២-៩៦ ព្រះរាជក្រឹត្យ នស/រកត ១២៩៦/បន្ធូរបន្ថយរយៈពេលរងទោសអោយទណ្ឌិត ២០៤០

២៤-១២-៩៦ ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៩៣ តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនិយឯក ជាកិច្ចមច្ចាមរណៈជូនសព្វលោក ឧត្តមសេនិយ ទោ ឡុង សុភាព ២០៥០

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១– អនុក្រឹត្យ

៣០-១២-១៩៩៦ អនុក្រឹត្យលេខ ២០៥ អនក្រ. តត. ស្តីពីការតែងតាំងមន្ត្រី រាជការ ២០៥២

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៤–១២–១៩៩៦ ប្រកាសលេខ ២៧១ ឧក.ប្រក. អនុញ្ញាតអោយក្រុមហ៊ុនតូតាល់ កម្ពុជា (TOTAL CAMBODGE) តំណាងដោយលោក Jean Mare Roger ANDRE សញ្ជាតិបារាំង បង្កើត « រោងចក្រ បញ្ចូលឧស្ម័នក្នុងដប » មានឈ្មោះថា «រោងចក្របញ្ចូល ឧស្ម័នតូតាល» ២០៥៣

២៤–១២–១៩៩៦ ប្រកាសលេខ ៧២២ ឧក.ប្រក. អនុញ្ញាតអោយលោក ហ៊ុយ សុខ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិន ស្រូវកំលាំង ៣០ សេះ ២០៥៤

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៣ ឧក.ប្រក. អនុញ្ញាតអោយលោក សុខ ខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ២០៥៥

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៤ ផក.ប្រក. អនុញ្ញាតអោយលោក **យុំ ណោរ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៧ សេះ ២០៥៦

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៥ផក.ប្រ. អនុញ្ញាតអោយលោក **ឆាយ ហាច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧០ សេះ ២០៥៦

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៦ ផក.ប្រក. អនុញ្ញាតអោយលោក **សំ ហាក់** ជនជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥៩សេះ ២០៥៧

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៧ ផក.ប្រក. អនុញ្ញាតអោយលោក **សំ ហាច់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៩០ សេះ ២០៥៨

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៨ ផក.ប្រក. អនុញ្ញាតអោយឧស្សាហកម្មតូច ផលិតទឹកកកអនាម័យ និង បង្កក មានលោក **តួច តូសិរិ - ធីរះតួច** ជនជាតិថៃ សញ្ជាតិថៃ ជាប្រធាន ២០៥៩

២៤-១២-១៩៩៦ ប្រកាសលេខ ៧២៩ ផក.ប្រក. អនុញ្ញាតអោយរោងចក្រផលិតទឹកកក ទឹកក្រូច មានអ្នកស្រី **គីម គាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបើកដំណើរការផលិតកម្ម ២០៥៩

២៤-១២-១៩៩៦ ប្រកាសលេខ ៧៣០ ផក.ប្រក. អនុញ្ញាតអោយលោក **ខាត់ សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម ២០៦០

២៤-១២-១៩៩៦ ប្រកាសលេខ ៧៣១ ផក.ប្រក. អនុញ្ញាតអោយលោកស្រី **ស៊ីម ឡាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតល្ហ-ឥដ្ឋការ៉ូ ២០៦១

២៤-១២-១៩៨៦	ប្រកាសលេខ ៧៣២ ផក.ប្រក. អនុញ្ញាតអោយលោក **ស៊ឹម ឡុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកអនាម័យ	២០៦១
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៣ ផក.ប្រក. អនុញ្ញាតអោយលោក **ឃុ លាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្ម តូចផលិតសំភារៈប្រើប្រាស់អំពីអាលុយមីញ៉ូម	២០៦២
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៤ ផក.ប្រក. អនុញ្ញាតអោយលោក **អ៊ើល ដារ៉ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតគ្រឿង	២០៦៣
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៥ ផក.ប្រក. អនុញ្ញាតអោយលោក ស៊ុម ស្រួយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរសិប្បកម្មផលិតទឹកត្រី	២០៦៣
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៦ ផក.ប្រក. អនុញ្ញាតអោយលោកស្រី **ឃួ ណាទី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតឆ្នាំងអាលុយមីញ៉ូមរឹងយីហោ « អង្គរ »	២០៦៤
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៧ ផក.ប្រក. អនុញ្ញាតអោយ **យ៉ិន តារ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៩០ សេះ	២០៦៤
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៨ ផក.ប្រក. អនុញ្ញាតអោយលោក **លី ដា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ	២០៦៥
២៤-១២-១៩៨៦	ប្រកាសលេខ ៧៣៩ ផក.ប្រក. អនុញ្ញាតអោយលោក **ទ៊ាន់ ឌួ** ជនជាតិខ្មែរ សញ្ជាតកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣៦ សេះ	២០៦៦

២៤-១២-១៩៩៦	ប្រកាសលេខ ៧៤០ ផក.ប្រក.អនុញ្ញាតអោយលោក **ឆើយ ម៉ន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៧៥ សេះ	២០៦៦
២៤-១២-១៩៩៦	ប្រកាសលេខ ៧៤១ ផក.ប្រក.អនុញ្ញាតអោយលោក **ហុង ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ	២០៦៧
៣០-១២-១៩៩៦	ប្រកាសលេខ ៧៤២ ផក.ប្រក.អនុញ្ញាតអោយលោក **ខៀវ ជន** ជនជាតិខ្មែរ សញ្ជាតកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ	២០៦៨
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥០ ផក.ប្រក.អនុញ្ញាតអោយលោក **សុក គួង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៦៨
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥១ ផក.ប្រក.អនុញ្ញាតអោយអ្នកស្រី **នៅ ចាន់ថុល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ	២០៦៩
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥៨ ផក.ប្រក.អនុញ្ញាតអោយម៉ាស៊ីនកិនស្រូវមានអ្នកស្រី **ម៊ូ សារឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ	២០៧០
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥៣ ផក.ប្រក.អនុញ្ញាតអោយលោក **ហ៊ា សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៤៥ សេះ	២០៦៧

៣០-១២-១៩៩៦	ប្រកាសលេខ ៧៥៤ ផក. ប្រក. អនុញ្ញាតអោយលោក **ចេង គួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម និង ការ៉េម	២០៧១
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥៦ ផកប្រក. អនុញ្ញាតអោយលោក **ហែម អ៊ែង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	២០៧២
៣០-១២-១៩៩៦	ប្រកាសលេខ ៧៦៧ ផក. ប្រក. អនុញ្ញាតអោយលោក **លឹម ជុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចក្រឡឹង និងកិនដែក	២០៧៣
៣០-១២-១៩៩៦	ប្រកាសលេខ ៧៥៨ ផក. ប្រក. អនុញ្ញាតអោយលោក **ឈាង ហុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	២០៧៣
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦០ ផក. ប្រក. អនុញ្ញាតអោយលោក **នួន ជុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៧៤
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦១ ផក. ប្រក. អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវមានលោក **ខាង ការ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធាន បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៣៧ សេះ	២០៧៥
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦២ ផក. ប្រក. អនុញ្ញាតអោយលោក **លីម ឆាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣៣ សេះ	២០៧៥
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៣ ផក. ប្រក. អនុញ្ញាតអោយលោក **ឌួច ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការផលិតកម្ម ដោយម៉ាស៊ីន ៥០ សេះ	២០៧៦

៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៤ ផក.ប្រក. អនុញ្ញាតអោយលោក **ទេន ម៉ាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងជួសជុលគ្រឿងបន្លាស់ម៉ូតូ	២០៧៧
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៥ ផក.ប្រក. អនុញ្ញាតអោយសិប្បកម្មផលិតធុងដែកអ៊ីណុក មានលោក **តាំង លីសេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបើកដំណើរការផលិតកម្ម	២០៧៨
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៦ ផក.ប្រក. អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ មានលោក **ចៅ ឆោរ** ជនជាតិខ្មែរ សញ្ជាតកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៥១ សេះ	២០៧៨
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៧ ផក.ប្រក. អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ មានលោក **យឹម ស៊ាន** ជនជាតិខ្មែរ សញ្ជាតកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្ម ប្រើម៉ាស៊ីនកំលាំង ៧៧ សេះ	២០៧៩
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៨ ផក.ប្រក. អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ មានលោក **ឆាង ហ៊ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្មប្រើម៉ាស៊ីនកំលាំង ៥០ សេះ	២០៨០
៣១-១២-១៩៩៦	ប្រកាសលេខ ៧៦៩ ផក.ប្រក. អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ មានលោក **សៀ ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ	២០៨១
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧០ ផក.ប្រក. អនុញ្ញាតអោយលោក **ឡាយ ហ៊ុគីម** ជនជាតិខ្មែរ សញ្ជាតកម្ពុជា បើកដំណើរការឧស្សាហកម្មផលិតទឹកបរិសុទ្ធ « បូតោ » និងទឹកបរិសុទ្ធ	២០៨១

៣១-០១-១៩៩៦	ប្រកាសលេខ ៧៧១ ផក.ប្រក.អនុញ្ញាតអោយអ្នកស្រី **ឃូ ហៀក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	២០៨២
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧២ ផក.ប្រក.អនុញ្ញាតអោយលោក **ថៃ ឈាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២ សេះ	២០៨៣
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៣ ផក.ប្រក.អនុញ្ញាតអោយលោក **រស់ ទង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតកម្ម ទឹកកកដើម	២០៨៤
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៤ ផក.ប្រក.អនុញ្ញាតអោយលោក **ឆរ អាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៨៥
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៥ ផក.ប្រក.អនុញ្ញាតអោយលោក **ឆរ ឈាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនទឹកកកដើម	២០៨៥
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៦ ផក.ប្រក.អនុញ្ញាតអោយលោក ហ៊ិន ស៊ិទ្ធ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការមេស្សាហកម្មតូចផលិតទឹកកកដើម	២០៨៦
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៧ ផក.ប្រក.អនុញ្ញាតអោយលោក **លឹម អ៊ី** ជនជាតិខ្មែរ សញ្ជាតកម្ពុជា បន្តដំណើរការសិប្បកម្មឥដ្ឋ–ក្បឿង	២០៨៧
៣១-១២-១៩៩៦	ប្រកាសលេខ ៧៧៨ ផក.ប្រក.អនុញ្ញាតអោយលោក **លឹម អ៊ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការផលិតនំបុ័ង យីហោ « នាងនាគគ្រោចចរ »	២០៨៧

៣១-១២-១៩៨៦	ប្រកាសលេខ ៧៧៩ ផក.ប្រក. អនុញ្ញាតអោយលោក **ហ៊ុយ គី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	២០៨៨
៣១-១២-១៩៨៦	ប្រកាសលេខ ៧៨២ផក.ប្រក. អនុញ្ញាតអោយលោក **ហេង ឡុង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងជាងកែច្នៃ និង ផលិតគ្រឿងសង្ហារឹមពីដើមកោ	២០៨៩
៣១-១២-១៩៨៦	ប្រកាសលេខ ៧៨៣ ផក.ប្រក. អនុញ្ញាតអោយឧស្សាហកម្មតូច ផលិតស្ករស មានលោក **ពិត សឿក** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្ម	២០៩០
៣១-១២-១៩៨៦	ប្រកាសលេខ ៧៨៤ ផក.ប្រក. អនុញ្ញាតអោយអ្នកស្រី **សុខ ផល្លា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការ សិប្បកម្មផលិតម្សៅឆា និង ម្សៅនំ	២០៩១

២ - ឯកសារការរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

៣០-១២-១៩៨៦	ប្រកាសលេខ ៦៥៥ ប្រ.ក.កសក.បត. ស្តីពីការតែងតាំងសាស្ត្រាចារ្យគ្រូបង្រៀន ប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ១៩៨៧	២០៩២

៣ - ឯកសារការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

៣០-១២-១៩៨៦	ប្រកាសលេខ ៨៦ ប្រក.បល/៨៦ ស្តីពីការលុបឈ្មោះចេញពីក្របខ័ណ្ឌតុលាការ	២១០០

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៤-១២-១៩៨៦ ប្រកាសលេខ ៣៣១/៨៦ ពម.ប្រក. អនុញ្ញាតជូនលោក រស់ ចាំង បើកទូរទស្សន៍ខ្សែកាប បន្តផ្សាយនៅទីរួមខេត្តកោះកុង ២១០១

២៦-១២-១៩៨៦ ប្រកាសលេខ ៣៣៥/៨៦ ពម.ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០២

៥- ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

៣០-១២-១៩៨៦ ប្រកាសលេខ ២៣៣ ប្រ.ក.វវឈបុ. ស្តីពីការទទួលស្គាល់លទ្ធផលនៃការប្រឡងយកវិញ្ញាបនប័ត្រសិល្បៈ ផ្នែកសិល្បៈតូរ្យតន្ត្រី ជំនាន់ទី ១ ២១០៤

៦- ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

២៤-១២-១៩៨៦ ប្រកាសលេខ ១០២៩ អយកប្រក. ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា អង្គតាព្រះ មកជាសាលាបឋមសិក្សា ហ៊ុន សែន អង្គតាព្រះ ២១០៦

២៤-១២-១៩៨៦ ប្រកាសលេខ ១០៣០ អយកប្រក. ស្តីពីការប្តូរឈ្មោះសាលាអនុវិទ្យាល័យ អង្គតាព្រះ ទៅជាអនុវិទ្យាល័យ ហ៊ុន រ៉ានី ហ៊ុន សែន អង្គតាព្រះ ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ២១០៧

២៦-១២-១៩៨៦ ប្រកាសលេខ ១០៣៧ អយក.ប្រក. ស្តីពីការបើកអនុវិទ្យាល័យតាអូ ក្នុងឃុំអូ ស្រុកគីរីវង់ ខេត្តតាកែវ ២១០៩

ង

៧- ទីស្ដីការ ក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៧៣/៨៦ កកធស អនុញ្ញាតជាគោលការណ៍ អោយបើកសាលាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដនិកាយប្រូតេស្តង់ ឈ្មោះព្រះវិហារ «ទីករស» នៅឃុំ តា ស្រុកមោងឫស្សី ខេត្ត បាត់ដំបង	២១១១
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៧៤/៨៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកសាលាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ដនិកាយសេវេនដោយអាត់វេនទីស្ដ ស្រុកបាពណ៌ ខេត្តកំពង់ធំ	២១១៤
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៧៥/៨៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រីស្ដ នៃវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្ដីមេត្ដាករុណា នៃព្រះគ្រីស្ដ» ខេត្តតាកែវ	២១១៥
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៧៦/៨៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកសាលាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ដវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្ដីមេត្ដាករុណា នៃព្រះគ្រីស្ដ» ខេត្តស្វាយរៀង	២១១៦
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៧៧/៨៦ កធស. អនុញ្ញាតជាគោលការណ៍ អោយរៀបចំ និង បើកសាលាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ដនិកាយកាតូលិក	២១១៨
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៨០ កធស/៨៦ អនុញ្ញាតជាគោលការណ៍ អោយបើកសាខាថ្វាយបង្គំព្រះគ្រិស្ដនិកាយ កាតូលិកនៅភូមិ ១ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម	២១២១
៣១-១២-១៩៨៦	សេចក្ដីសំរេចលេខ ២៨១/៨៦ កធស. អនុញ្ញាតអោយបើកស្នាក់	

	ការថ្វាយបង្គំព្រះគ្រីស្ទ ព្រះវិហារឈ្មោះ « ពួកជំនុំខ្វារថ្មី »	២១១៩
៣១-១២-១៩៩៦	សេចក្តីសំរេចលេខ ២៨២/៩៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះ គ្រីស្ទនិកាយប្រូតេស្តង់ ឈ្មោះវិហារ « ក្រុមជំនុំសេចក្តីសុចរិត »	២១២១
៣១-១២-១៩៩៦	សេចក្តីសំរេចលេខ ២៨៣/៩៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាមីលីក ឃុំស្វាយ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម	២១២៣
៣១-១២-១៩៩៦	សេចក្តីសំរេចលេខ ២៨៤/៩៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយប្រូតេស្តង់ ឈ្មោះ « ដំណឹងល្អមេត្តូឌីស្ទខ្មែរ » នៅឃុំតាក្តុល ស្រុកតាខ្មៅ ខេត្តកណ្តាល	២១២៤
៣១-១២-១៩៩៦	សេចក្តីសំរេចលេខ ២៨៥/៩៦ កធស. អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃព្រះវិហារឈ្មោះ « ព្រះយេស៊ូគ្រីស្ទជាម្ចាស់សន្តិភាពរបស់យើង »	២១២៦

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/១២៩៦/៣៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ឧភតោសុជាត ទិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីអំពីតំបន់ដីសើម មានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជំរកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាំសា ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ១៩៧១ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ នាសម័យ ប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើម មានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជំរកសត្វស្លាបទឹក

ចុះនៅទីក្រុងរ៉ាំសា ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៧១

មាត្រា ១ : អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជំរកសត្វស្លាបទឹក ដែលធ្វើនៅទីក្រុងរ៉ាំសា ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៧១ ព្រមទាំងបណ្តាវិសោធនកម្មនៃអនុសញ្ញានេះ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២ : រាជរដ្ឋាភិបាលកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
ហត្ថលេខា
ម៉ុក ម៉ារ៉េត

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា
ហ៊ុន សែន

* * *

ព្រះរាជក្រម នស/រកម/១២៩៦/៣៥

ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌនៃសហប្រជាជាតិ ស្តីពីការផ្លាស់ប្តូរធាតុអាកាស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាល ទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្ដីពី

ការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌនៃសហប្រជាជាតិ

ស្ដីពី

ការផ្លាស់ប្ដូរធាតុអាកាស

មាត្រា ១ : អនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌនៃសហប្រជាជាតិ ស្ដីពីការផ្លាស់ប្ដូរធាតុអាកាស ដែលធ្វើនៅញូវយ៉ក នាថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្ដលេខា

នរោត្ដម សីហនុ

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីទី១ និងទី២
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
ហត្ថលេខា
ម៉ុក ម៉ារ៉េត

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្ដលេខា ហត្ថលេខា
នរោត្ដម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រម នស/រកម/១២៩៦/៣៦

ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រកាសអោយប្រើ

ច្បាប់ស្តីពី កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្តីពី

កិច្ចការពារបរិស្ថាន

និង

ការគ្រប់គ្រងធនធានធម្មជាតិ

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : ច្បាប់នេះ មានគោលដៅ ÷

- ការពារ លើកកំពស់គុណភាពបរិស្ថាននិងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយនិងការត្រួតពិនិត្យការបំពុល
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង ។
- ធានាអោយមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- លើកទឹកចិត្ត និង ផ្តល់លទ្ធភាពអោយសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើអោយប៉ះពាល់ដល់បរិស្ថាន ។

ជំពូកទី ២

ផែនការបរិស្ថានជាតិនិងផែនការបរិស្ថានតំបន់

មាត្រា ២ : ផែនការបរិស្ថានជាតិ ផែនការបរិស្ថានតំបន់ ត្រូវសិរៀបចំដោយ រាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

មាត្រា ៣ : ផែនការបរិស្ថានជាតិ ជាផែនការសំរាប់កិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរសំរាប់អនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផែនការបរិស្ថានជាតិត្រូវ ÷

- កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និង បញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។
- លើកឡើងពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាន ។

មាត្រា ៤ : ផែនការបរិស្ថានតំបន់ ត្រូវអនុលោមតាមផែនការបរិស្ថានជាតិ ។

ផែនការបរិស្ថានតំបន់ត្រូវ ÷

- កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និង បញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៃតំបន់នីមួយ ៗ
- លើកឡើងពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាននៃតំបន់នោះ ។

មាត្រា ៥ : ផែនការបរិស្ថានជាតិ និង ផែនការបរិស្ថានតំបន់ត្រូវពិនិត្យ និងកែសំរួលយ៉ាងយូរ មួយដងក្នុងរយៈពេល ៥ ឆ្នាំ ។

ជំពូកទី ៣

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មាត្រា ៦ : ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គំរោង និង សកម្មភាពរបស់ឯកជន ឬ សាធារណៈហើយត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

ការវាយតម្លៃនេះ ក៏ត្រូវបានអនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ប្រភេទ និង ទំហំគំរោង និង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការទាំងឯកជននិងសាធារណៈដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

មាត្រា ៧ : ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និង រាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវ ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៤

ការគ្រប់គ្រងធនធានធម្មជាតិ

មាត្រា ៨ : ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និង គ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរ ។

តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជំរកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

មាត្រា ៩ : ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និង ផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាអោយធនធានធម្មជាតិ ដូចមានចែងក្នុងមាត្រា ៨ ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ ដោយសមហេតុផលប្រកបដោយនិរន្តរភាពនិងភាពសស្ថិតស្ថេរ ។

មាត្រា ១០ : មុនពេលចេញសេចក្តីសំរេចនានាឬធ្វើសកម្មភាពផ្សេងៗ ទាក់ទិនដល់ការអភិរក្ស ការអភិវឌ្ឍន៍ ឬ ការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធត្រូវពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានអំពីនិរន្តរភាព និង ភាពស្ថិតស្ថេរនៃធនធានធម្មជាតិ ។

មាត្រា ១១ : ក្រសួងបរិស្ថានត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាក់ព័ន្ធ នៅពេលណាដែលក្រសួងបរិស្ថានពិនិត្យឃើញថា ធនធានធម្មជាតិមិនមានការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងការប្រើប្រាស់ ដោយសមហេតុផល និង ប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរនោះ ។

ជំពូកទី ៥

កិច្ចការពារបរិស្ថាន

មាត្រា ១២ : ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី ÷

- ប្រភព ប្រភេទនិងបរិមាណនៃសារធាតុបំពុលនិងសំណល់ ដែលបាននាំចូល បង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬ បញ្ចេញចោលទៅក្នុងអាកាស ទឹក ដីឬលើដី ។
- ប្រភព ប្រភេទនិងបរិមាណនៃសារធាតុពុលនិងសារធាតុ ប្រកបដោយគ្រោះថ្នាក់ ដែលបាននាំចូល ផលិតដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើង បានប្រព្រឹត្តកម្ម កែច្នៃឡើងវិញ បោះបង់ចោល ឬ ដែលបានបញ្ចេញចោលទៅក្នុងអាកាស ទឹកឬទៅក្នុងដីឬលើដី ។
- ប្រភព ប្រភេទនិងទំហំនៃការរំខានដោយសំលេងនិងរំញ័រ ។

មាត្រា ១៣ : ការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល អាកាស ទឹក ដី ការរំខាន ដោយសំលេងនិងរំញ័រព្រមទាំងសំណល់ សារធាតុពុល និង សារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ជំពូកទី ៦

ការត្រួតពិនិត្យ កំណត់ត្រា អធិការកិច្ច

មាត្រា ១៤ : ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីកំណត់អោយម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្ម ឬ តំបន់មានសកម្មភាពអភិវឌ្ឍន៍ធនធាន ធម្មជាតិនានា ÷

- តម្លើង ឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ
- ផ្តល់គំរូតាង

– រៀបចំឬរក្សាទុកនិងធ្វើជូនពិនិត្យនូវកំណត់ត្រានិងរបាយការណ៍នានា ។

មាត្រា ១៥ : ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន និង ក្នុងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ ទីក្នុងបរិវេណ អាគារលើឬក្នុង មធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ ។ល។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពនោះធ្វើអោយមានការប៉ះពាល់ដល់គុណភាពបរិស្ថាន ។

មន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថាននិងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និង លិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅមុនពេលធ្វើអធិការកិច្ច ។

នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌកើតឡើងនោះ មន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់ ។

នីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

ជំពូកទី ៧

ការចូលរួមរបស់សាធារណជននិងការស្រង់យកពត៌មាន

មាត្រា ១៦ : ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវពត៌មានពីសកម្មភាពរបស់ខ្លួន និង ត្រូវលើកទឹកចិត្តអោយមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ១៧ : បែបបទនៃការចូលរួមរបស់សាធារណជននិងការស្រង់យក ពត៌មានក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

មាត្រា ១៨ : ពត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ឬ ការគ្រប់គ្រងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមក រវាងក្រសួងបរិស្ថាន និងក្រសួងនានា ។

ជំពូកទី ៨

មូលនិធិទាយជ្ជទានបរិស្ថាន

មាត្រា ១៩ : ត្រូវបង្កើតគណនីពិសេសរបស់រតនាគារ ជាគណនីមូលនិធិទាយជ្ជទានបរិស្ថានសំរាប់អោយក្រសួងបរិស្ថាន យកទៅចាត់ចែងក្នុងកិច្ចការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិក្នុង ព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានបរិស្ថាន ដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និង ចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិ ដើម្បីផ្តល់អោយគណនីពិសេសខាងលើ ។

ជំពូកទី ៩

ទោសបញ្ញត្តិ

មាត្រា ២០ : ពោះបុគ្គលណា ដែលប្រព្រឹត្តិល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវចេញបញ្ជា ជាលាយលក្ខណ៍អក្សរតម្រូវអោយ ÷

- កែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ ឬ
- ផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ឬ
- លុបបំបាត់ការបំពុលជាបន្ទាន់ ។

មាត្រា ២១ : បុគ្គលណាមិនអនុញ្ញាត ឬរាំងមិនអោយមន្រ្តីអធិការកិច្ចចូលធ្វើការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចលើទីតាំងដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៥

នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ពីប្រាំសែនរៀល (៥០០.០០០រៀល) ដល់មួយលានរៀល (១.០០០.០០០រៀល) ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០រៀល) ឬ ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ៣ខែ ឬទោសទាំងពីរ នេះ ។

បុគ្គលណាប្រព្រឹត្តល្មើសនឹងមាត្រា ២០ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ដប់លានរៀល (១០.០០០.០០០រៀល) ។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីម្ភៃមួយលានរៀល (២១.០០០.០០០រៀល) ដល់សាមសិបលានរៀល (៣០.០០០.០០០រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬ ទោសទាំងពីរនេះ ។

មាត្រា ២២ : បើការប្រព្រឹត្តល្មើសបង្កអោយមានគ្រោះថ្នាក់ដល់រាងកាយ ឬ ជីវិតមនុស្ស ដល់ទ្រព្យសម្បត្តិឯកជន ដល់ទ្រព្យសម្បត្តិសាធារណៈ ដល់បរិស្ថាន ដល់ធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់ លានរៀល (១០.០០០.០០០រៀល)ដល់ហាសិបលានរៀល(៥០.០០០.០០០រៀល) ឬ ផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ ឬទោសទាំងពីរនេះ ។

បុគ្គលដែលប្រព្រឹត្តល្មើស ត្រូវទទួលជួសជុលសងការខូចខាតនិងសងជំងឺចិត្តថែមទៀត ។

មាត្រា ២៣ : ក្នុងករណីដែលការប្រព្រឹត្តល្មើសបង្កអោយមានគ្រោះមហន្តរាយធ្ងន់ធ្ងរ ចំពោះសង្គមជាតិ តុលាការអាចនឹងយកកាលៈទេសៈទម្ងន់ទោសទៅប្រកប ផ្សំនឹងបទល្មើសណាមួយខាងលើនេះដើម្បីផ្តន្ទាទោស ។

មាត្រា ២៤ : មន្ត្រី ឬ ភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នក

ប្រព្រឹត្ត បទល្មើសឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាលឬនឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

មាត្រា ២៥ : ក្រសួងបរិស្ថាន ត្រូវអនុវត្តទៅតាមបទបញ្ញត្តិនៃមាត្រា ២០ ខាងលើចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនិងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនិងបទបញ្ញត្តិនៃច្បាប់នេះ ។

ក្នុងករណីរឹងទទឹង ត្រូវអនុវត្តទៅតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ២១នៃច្បាប់នេះ ។

ជំពូកទី ១០

អន្តរបញ្ញត្តិ

មាត្រា ២៦ : ក្រោយពេលច្បាប់នេះចូលជាធរមាន រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ចំពោះសកម្ម ភាពដែលកំពុងដំណើរការបច្ចុប្បន្ន រាជរដ្ឋាភិបាលអាចពន្យារពេលការប្រតិបត្តិអនុក្រឹត្យ ដែលចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ក្នុងការសំរេចពន្យារពេលនេះត្រូវ ÷

- ថ្លឹងថ្លែងពីប្រភេទនិងទំហំនៃគ្រោះថ្នាក់ដល់សុខភាពមនុស្សដល់បរិស្ថាន និង ដល់ធនធានធម្មជាតិ ដែលអាចកើតឡើងពីការពន្យារពេលនេះ
- ពិនិត្យទៅលើលទ្ធភាព មធ្យោបាយ បច្ចេកទេសនិងហិរញ្ញវត្ថុរបស់សកម្មភាព ដែលកំពុងដំណើរការនេះ ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

មាត្រា ២៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ ព្រះហស្តលេខា **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២ ហត្ថលេខា **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី១ និងទី២

ហត្ថលេខា

ម៉ុក ម៉ារ៉េត

* * *

ព្រះរាជក្រម នស.រកម.១២៩៦-៣៧

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស- រកត- ១០៩៤- ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស- រកត- ១០៩៤- ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ប្រកាសអោយប្រើតាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកនិតិសម្បទា និង អភិវឌ្ឍន៍ និង ជាមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្តីពី

ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

ជំពូកទី១

បទបញ្ញត្តិទូទៅ

ស្តីពីចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

* * *

មាត្រា ១ : ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ១៩៩៧ អោយប្រមូលចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ ភាគទាន អាករផលទុនចំណូលនានា ព្រមទាំងធ្វើអោយសម្រេចនូវអំណោយមូលនិធិបដិភាគ និង ធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក "ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ....១.៤៩៦.៥០០ លានរៀល នឹងត្រូវបែងចែកដូចតទៅ ÷

- ចំណូលជាប្រចាំ ....៨៨៥.០០០ លានរៀល
- ចំណូលជាមូលធន...........................៦១១.៥០០ លានរៀល

មាត្រា ២ : ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ត្រូវបានកំណត់ស្មើនឹង .... ១.៤៩៦.៥០០ លានរៀល ដែលត្រូវបែងដូចតទៅ ÷

- ចំណាយជាប្រចាំ...........................៨៧០.០០០ លានរៀល
- ចំណាយជាមូលធន..........................៦២៦.៥០០ លានរៀល

មាត្រា ៣ : ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សម្រាប់ចំណាយជាប្រចាំរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ត្រូវបានកំណត់ស្មើនឹង .... ៨៧០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង ទៅតាមប្រភេទនៃ ថវិកាដូចមានចែងក្នុងតារាង" ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៤ : ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ - ១៩៩៩ ត្រូវបានកំណត់ស្មើនឹង.................៣.៨៨០.៨១០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមកម្មវិធី ឬ តាមគំរោង និង តាមឆ្នាំ ដូចមានចែង ក្នុងតារាង" គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៥ : ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយជាមូលធននៃថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ត្រូវបានកំណត់ដូចតទៅ ÷

ក– វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស

– ឥណទានភ្ជាប់សន្យា ....៧៣៣.០០០ លានរៀល

– ឥណទានទូទាត់ ....៤៨៨.០០០ លានរៀល

ខ– វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស

– ឥណទានភ្ជាប់សន្យា ....១២២.៨០០ លានរៀល

– ឥណទានទូទាត់ ....១២២.៨០០ លានរៀល

គ– ការរំលស់បំណុលសាធារណៈ

– ឥណទានភ្ជាប់សន្យា ....១៥.៧០០ លានរៀល

– ឥណទានទូទាត់ ....១៥.៧០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែកក្នុងតារាង "យ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៦ : ដើម្បីធានាការពារទប់ទល់នឹងការបាត់តុល្យភាពថវិកា ដែលបណ្តាលមកពីចំណូលមិនគ្រប់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយអនុលោមទៅតាមមាត្រា ៤៥ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ មានសិទ្ធិចាត់វិធានការរាំងខ្ទប់ ឥណទានលើចំណាយមិនចាំបាច់ នៅពេលណាដែលការប្រមូលពន្ធដារ ពន្ធនិងអាករលើពាណិជ្ជកម្មក្រៅប្រទេស ឬ ផលព្រៃឈើមិនគ្រប់តាមគម្រោងថវិកា ដែលរដ្ឋសភាបានអនុម័ត ហើយចំណូលមិនគ្រប់នេះ បេះតែបន្តរហូតដល់រយៈពេល ៣ខែ ។ នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះ ឥណទានរាំងខ្ទប់ មិនមែនជាឥណទានទំនេរសម្រាប់រដ្ឋមន្ត្រីជាអាណាប័កដើមខ្សែនិងអភិបាលខេត្ត ក្រុង ជាអាណាប័កផ្ទេរសិទ្ធិទៀតទេ ។

គ្រប់កិច្ចសន្យាចំណាយលើឥណទានដែលបានរាំងខ្ទប់ ត្រូវទុកជាមោឃៈនិងមិនមានអានុភាពអ្វីចំពោះរតនាគារទេ ។

ជំពូកទី ២

បទបញ្ញត្តិ

ស្តីពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

មាត្រា ៧ : ហាមឃាត់ដាច់ខាត មិនអោយប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែព្រមទាំងអាណាប័កផ្ទេរសិទ្ធិ ចាត់វិធានការទាំងឡាយណា ដែលនាំអោយកើនចំណាយលើឥណទានថវិកាទូទៅរបស់រដ្ឋ ដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ឬច្បាប់អនុក្រឹត្យនិងបទបញ្ញាដែលមានពីមុនកិច្ចសន្យាចំណាយ ។

មាត្រា ៨ : ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ សន.៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានចាត់ទុកជាកំហុសនៃការគ្រប់គ្រង ដែលបានប្រព្រឹត្តចំពោះរដ្ឋដូចជា :

- រាល់អំពើដែលប្រព្រឹត្តល្មើសនិងបទបញ្ញត្តិ ដូចមានចែងក្នុងជំពូកទីពាខាងក្រោមនេះ ។
- រាល់អំពើដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកា ដែលបានអនុម័តដោយរដ្ឋសភាលើកលែងតែឥណទានដែលបានគ្រោងទុកសម្រាប់បើកបៀវត្ស និងប្រាក់វិភាជន៍សង្គម សោហ៊ុយបំណុល និងសងប្រាក់ខ្ចីដែលបានយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិ ។
- រាល់អំពើដែលជាកម្មវត្ថុ សម្រាប់បង្កើនទឹកប្រាក់ឥណទានថវិកាដែលបានទទួលការអនុញ្ញាតពីរដ្ឋសភា ដោយធនធានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់ និងបទបញ្ញាជាធរមាន និងដោយអនុសញ្ញាអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តយល់ព្រម ។
- រាល់កំហុសធ្ងន់ធ្ងរ ដែលនាំអោយមានការខាតបង់ប្រាក់កាសដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។
- រាល់សកម្មភាពគ្រប់គ្រងដែលប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ និង បទបញ្ញាដែលអនុវត្តចំពោះចំណូល និងចំណាយរបស់រដ្ឋ ។

មាត្រា ៩ : ប្រធានស្ថាប័នរដ្ឋបាល អាណាប័កដើមខ្សែនិងអាណាប័កផ្ទេរសិទ្ធិ ព្រមទាំងមន្ត្រីរាជការ និង ភ្នាក់ងាររដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

[illegible] ៤៨ [illegible]

[illegible] : ៦ [illegible]

[illegible] ៦៧ [illegible] ១០ [illegible]

ជំពូកទី ៣

បទប្បញ្ញត្តិ

[illegible] ៣៦៦១ [illegible]

ស្តីពីការខ្ចីនិងការធានារបស់រដ្ឋ

[illegible] និងហិរញ្ញវត្ថុ ត្រូវ បានអនុញ្ញាតអោយខ្ចីមានកំរិតរហូតដល់ [illegible]០០ S.D.R(មួយរយ [illegible] –

[illegible] ហិរញ្ញវត្ថុ ជាអ្នក [illegible] លក្ខណ៍អក្សរ [illegible] ក្នុងការចុះហត្ថលេខា លើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ [illegible] ការធានារបស់រដ្ឋ ។

[illegible] មានលក្ខណៈជាការខ្ចី [illegible] ប៉ុន្តែរដ្ឋមន្ត្រីក្រសួង [illegible] ធនាគារជាតិនៃកម្ពុជា ត្រូវបានទទួល [illegible] កំរិតទឹកប្រាក់ចំនួន [illegible] សម្រាប់ដោះស្រាយ តម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ [illegible] ធនាគារនេះ [illegible] ខ្ចីនិងការធានារបស់ [illegible] ១៩៩៧ ត្រូវហាម [illegible] : ៦ [illegible]

[illegible] មួយ មានសិទ្ធិ ចុះហត្ថលេខា [illegible] មធ្យម ខ្ចី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានា កិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះ

កិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង លក្ខខណ្ឌ[illegible] ។

មាត្រា ១២ : លក្ខខណ្ឌទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យ [illegible] សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍បទបញ្ញត្តិនៃជំពូកនេះ ជូនរដ្ឋសភារៀងរាល់ ៦ ខែម្តង ។

ជំពូកទី ៤

អវសានបញ្ញត្តិ

មាត្រា ១៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ : ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

បានបង្គំទូលថ្វាយ និង ជំរាបជូន ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២ ព្រះហស្តលេខា

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិវឌ្ឍន៍ **នរោត្តម សីហនុ**

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ហត្ថលេខា សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

គាត ឈន់ នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា ហត្ថលេខា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស.រកត ១២៩៦–៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តមធម្មិក មហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

*****

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ធូរបន្ថយរយៈពេលរងទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ២១នាក់ ដែលមានរាយឈ្មោះខាងក្រោម ÷

១–ទណ្ឌិតឈ្មោះ **ម៉ក់ ម៉ុច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ៣.៤.៩៦ របស់តុលាការក្រុងភ្នំពេញ ។

២–ទណ្ឌិតឈ្មោះ **យឹម ពុតធីតា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ១ចុះថ្ងៃទី ១១.០៣.៩៥ របស់តុលាការក្រុងភ្នំពេញ ។

៣–ទណ្ឌិតឈ្មោះ **ខាន់ យឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ១.៤.៩៥ របស់តុលាការក្រុងភ្នំពេញ ។

៤–ទណ្ឌិតឈ្មោះ **រឿន សុផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ក ចុះថ្ងៃទី ២៧.៥.៩៥ របស់តុលាការក្រុងភ្នំពេញ ។

៥–ទណ្ឌិតឈ្មោះ **ចិន ចិន្តា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧គ ចុះថ្ងៃទី ៩.៨.៩៥ របស់តុលាការខេត្តកំពង់ចាម ។

៦–ទណ្ឌិតឈ្មោះ **ខុំ សុផាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ១.៧.៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៧–ទណ្ឌិតឈ្មោះ **ម៉ូន នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤៦ ចុះថ្ងៃទី ២៥.៧.៩៣ របស់តុលាការខេត្តកំពត ។

៨–ទណ្ឌិតឈ្មោះ **ជួន នុយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២៦.២.៩២ របស់តុលាការខេត្តបាត់ដំបង ។

៩–ទណ្ឌិតឈ្មោះ **សេក សន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ១០.៧.៩២ របស់តុលាការក្រុងភ្នំពេញ ។

១០–ទណ្ឌិតឈ្មោះ **ឡេវ៉ុនធី ទ៊ុកហាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១០.៦.៩៣ របស់តុលាការក្រុងភ្នំពេញ ។

១១–ទណ្ឌិតឈ្មោះ **អឿន ស៊ីវ៉ាម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី ២៩.១០.៩១ របស់តុលាការខេត្តស្វាយរៀង ។

១២–ទណ្ឌិតឈ្មោះ **ចន្ទ នារី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៩.៧.៩២ របស់តុលាការខេត្តបាត់ដំបង ។

១៣–ទណ្ឌិតឈ្មោះ **ចិន សារិទ្ធ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ៣១.៧.៩២ របស់តុលាការខេត្តបាត់ដំបង ។

១៤–ទណ្ឌិតឈ្មោះ **ជួន អ៊ឹ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ៦.១០.៨៧ របស់តុលាការខេត្តកំពង់ឆ្នាំង ។

១៥–ទណ្ឌិតឈ្មោះ **សាន សុខា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ១៥.១០.៩០ របស់តុលាការខេត្តកំពង់ចាម ។

១៦–ទណ្ឌិតឈ្មោះ **សៅ សន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ១.៧.៩២ របស់តុលាការខេត្តកំពង់ចាម ។

១៧–ទណ្ឌិតឈ្មោះ **ហែម ខាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ២១.២.៩៤ របស់តុលាការខេត្តកណ្តាល ។

១៨–ទណ្ឌិតឈ្មោះ **ខែម ង៉ែ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ២១.២.៨៩ របស់តុលាការខេត្តពោធិ៍សាត់ ។

១៩–ទណ្ឌិតឈ្មោះ **យ៉ែម អុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមដំណោងគ្មាន់ ចុះថ្ងៃទី ១.២.៩៣ របស់តុលាការខេត្តបាត់ដំបង ។

៣០– ទណ្ឌិតឈ្មោះ ស៊ុន ចាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣០ឆ្នាំ តាមសាលាដីកាលេខ ២ ចុះថ្ងៃទី ២៧.៧.៨៧ របស់តុលាការខេត្តកំពង់ចាម ។

៣១– ទណ្ឌិតឈ្មោះ ញ៉ែម សោមឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៧ឆ្នាំ តាមសាលាដីកាលេខ ២៣ ចុះថ្ងៃទី ២.១០.៩១ របស់តុលាការខេត្តកំពង់ចាម ។

មាត្រា ២.– ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ៦នាក់ ដូចមានរាយឈ្មោះខាងក្រោម៖

១– ទណ្ឌិតឈ្មោះ គុណ សៀម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមសាលាដីកាលេខ ៣០ប្រ ចុះថ្ងៃទី ៣.៦.៩៥ របស់តុលាការក្រុងភ្នំពេញ ។

២– ទណ្ឌិតឈ្មោះ ឆា ឈាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមសាលាដីកាលេខ ៤០០ ចុះថ្ងៃទី ១៥.១០.៩៤ របស់តុលាការក្រុងភ្នំពេញ ។

៣– ទណ្ឌិតឈ្មោះ ឱម ឡេងម៉ុកឆ្វេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមសាលាដីកាលេខ ៤០០ ចុះថ្ងៃទី ១៥.១០.៩៤ របស់តុលាការក្រុងភ្នំពេញ ។

៤– ទណ្ឌិតឈ្មោះ ឆន ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមសាលាដីកាលេខ ១២ ចុះថ្ងៃទី ២៥.១.៩៦ របស់តុលាការខេត្តសៀមរាប ។

៥– ទណ្ឌិតឈ្មោះ ហ៊ូ ផាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមសាលាដីកាលេខ ៥ ចុះថ្ងៃទី ២៣.២.៩៥ របស់តុលាការខេត្តកំពង់ចាម ។

៦–ទណ្ឌិតឈ្មោះ **ជុះ ឆឿម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ៤.១.៩៦ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

៧–ទណ្ឌិតឈ្មោះ **ឈុំ ឈឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ២២.៥.៩៦ របស តុលាការខេត្តកំពង់ធំ ។

៨–ទណ្ឌិតឈ្មោះ **ស៊ាន ម៉ន** ដែលត្រូវបានផ្តន្ទា ដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ ចុះថ្ងៃទី ១៥.៨.៩៥ របស់តុលាការខេត្តកំពង់ធំ ។

៩–ទណ្ឌិតឈ្មោះ **ម៉ុម ម៉ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រម លេខ ៤៩ ចុះថ្ងៃទី ៣១.៧.៩៤ របស់ តុលាការខេត្តកំពង់ធំ ។

១០–ទណ្ឌិតឈ្មោះ **សែត ពែត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ២២.២.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១១–ទណ្ឌិតឈ្មោះ **គីម សារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២៥ឆ្នាំ តាមអំណាចសាល ក្រមលេខ ៣៥ ចុះថ្ងៃទី ២២.២.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១២–ទណ្ឌិតឈ្មោះ **តៅ តឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រម លេខ ៣៦ ចុះថ្ងៃទី ២២.២.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៣–ទណ្ឌិតឈ្មោះ **សែម នាង** ហៅលន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ ចុះថ្ងៃទី ២១.០៣.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៤-ទណ្ឌិតឈ្មោះ **ហាច ហ៊ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៨ ចុះថ្ងៃទី ២៦.៦.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៥-ទណ្ឌិតឈ្មោះ **ម៉ក់ ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៨ ចុះថ្ងៃទី ២៦.៦.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៦-ទណ្ឌិតឈ្មោះ **ស៊ុខ សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៤ ចុះថ្ងៃទី ១៨.៧.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៧-ទណ្ឌិតឈ្មោះ **ខឹន សុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ២០៨ ចុះថ្ងៃទី ៣.៨.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៨-ទណ្ឌិតឈ្មោះ **ណែល សឿខ** ហៅវណ្ណា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមសាលក្រមលេខ ៣៧៤ ចុះថ្ងៃទី ២២.១២.៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៩-ទណ្ឌិតឈ្មោះ **ថ្លាង ជឿម** ហៅឈឿម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ២៣.២.៩៦ របស់តុលាការខេត្តបាត់ដំបង ។

២០-ទណ្ឌិតឈ្មោះ **សែម យឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៥ ចុះថ្ងៃទី ៩.៤.៩៦ របស់តុលា ការខេត្តបាត់ដំបង ។

២១-ទណ្ឌិតឈ្មោះ **ទ័ន ទិត** ហៅនី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥០ ចុះថ្ងៃទី ៤.៧.៩៦ របស់តុលាការខេត្តបាត់ដំបង ។

២២-ទណ្ឌិតឈ្មោះ **ណៃរ ឌី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ ចុះថ្ងៃទី ៨.៨.៩៦ របស់តុលាការខេត្តក្រចេះ ។

២៣-ទណ្ឌិតឈ្មោះ **ឡាំ ខេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ព្យួរទោស ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៣ ក ចុះថ្ងៃទី ២២.១២.៩៥ និងដាក់ពន្ធនាគារកំណត់ ១ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ព ចុះថ្ងៃទី ៦.២.៩៦ របស់តុលាការខេត្តកណ្តាល ។

២៤-ទណ្ឌិតឈ្មោះ **នួន សាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ត ចុះថ្ងៃទី ១៧.៦.៩៦ របស់តុលាការខេត្តកំពង់ចាម ។

២៥-ទណ្ឌិតឈ្មោះ **ទើន ចន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ត ចុះថ្ងៃទី ១២.១១.៩៦ របស់តុលាការខេត្តកំពង់ចាម ។

២៦-ទណ្ឌិតឈ្មោះ **ចៀម ចិត្ត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៩ ចុះថ្ងៃទី ១២.៧.៩៦ របស់តុលាការខេត្តសៀមរាប ឧត្តមមានជ័យ ។

២៧-ទណ្ឌិតឈ្មោះ **ទឹម សុខឃីន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ២៣.៨.៩៤ របស់តុលាការខេត្តបន្ទាយមានជ័យ ។

២៨-ទណ្ឌិតឈ្មោះ **ឈឹម នេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ១១.៣.៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

២៩–ទណ្ឌិតឈ្មោះ **មូល ជុំក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ៧.៦.៩៦ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣០–ទណ្ឌិតឈ្មោះ **ជុំន ស៊ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ១៥.១១.៩៥ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣១–ទណ្ឌិតឈ្មោះ **ចាក ទ៉ាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ ចុះថ្ងៃទី ២៩.៣.៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៣២–ទណ្ឌិតឈ្មោះ **ញៀម ហៀង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ២០.១០.៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៣៣–ទណ្ឌិតឈ្មោះ **ស្រួយ ស្រ៊ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់មួយជីវិត តាមអំណាច សាលក្រមលេខ ១ ចុះថ្ងៃទី ២៦.៥.៨៣ របស់តុលាការក្រុងភ្នំពេញ ។

៣៤–ទណ្ឌិតឈ្មោះ **យឹម ស្រ៊ាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២៧.៦.៨៧ របស់តុលាការខេត្តកំពត ។

៣៥–ទណ្ឌិតឈ្មោះ **ឈឿន សឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ២៦.៦.៩២ របស់តុលាការក្រុងភ្នំពេញ ។

៣៦–ទណ្ឌិតឈ្មោះ **ទ៉ា ស្រី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៩.៩.៨៧ របស់តុលាការយោធា ។

៣៧–ទណ្ឌិតឈ្មោះ **ឡាំ ម៉ីឈាង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ខែ តាមអំណាចសាលក្រមលេខ ៨១ ក ចុះថ្ងៃទី ២៧.៦.៩៦ របស់តុលាការខេត្តកំពង់ចាម ។

៣៨–ទណ្ឌិតឈ្មោះ **លឹម ចិន្តា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ (ទោសគុក ១៨ខែ ព្យួរទោស ១៨ខែ) តាមអំណាចសាលក្រមលេខ១០៦ ចុះថ្ងៃទី ១០.៥.៩៦ របស់តុលាការខេត្តបាត់ដំបង។

៣៩–ទណ្ឌិតឈ្មោះ **សុខ គី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ៧.៤.៩៤ របស់តុលាការខេត្តបាត់ដំបង ។

៤០–ទណ្ឌិតឈ្មោះ **យ៉ឹន គំណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ១១.១.៩៦ របស់តុលាការខេត្តបាត់ដំបង ។

៤១–ទណ្ឌិតឈ្មោះ **ម៉ូ ម៉ុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ជាប់គុកប្រាក់ធនទណ្ឌតាមអំណាចសាលក្រមលេខ១ ចុះថ្ងៃទី ១០.១.៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៤២–ទណ្ឌិតឈ្មោះ **ហាម សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ ចុះថ្ងៃទី ២៥.១១.៩៣ របស់តុលាការក្រុងភ្នំពេញ ។

៤៣–ទណ្ឌិតឈ្មោះ **ជាំង ឆឺឌីយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ៩.២.៩៦ របស់តុលាការក្រុងព្រះសីហនុ ។

៤៤–ទណ្ឌិតឈ្មោះ **សយ ស្រីម៉ៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ផុតរយៈពេលរងទោស របស់តុលាការខេត្តបាត់ដំបង ។

៤៥–ទណ្ឌិតឈ្មោះ **ទៀន សុផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ក ចុះថ្ងៃទី ២៧.៥.៩៦ របស់តុលាការក្រុងភ្នំពេញ ។

៤៦–ទណ្ឌិតឈ្មោះ **សៅ សុវណ្ណារី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ខ ចុះថ្ងៃទី ១០.៩.៩៦ របស់តុលាការក្រុងភ្នំពេញ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

មាត្រា ៤ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១២៩៦/៩៣

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជ-រដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ

